00287829

**Declassified to Public**
**06 September 2012**

E2/94/3

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០១/១៨-០៧-២០០៧-អ វ តក/ អង្គជំនុំជម្រះសាលាដំបូង |
| ដាក់នៅចំពោះមុខ | ៖ | អង្គជំនុំជម្រះសាលាដំបូង |
| កាលបរិច្ឆេទឯកសារ | ៖ | ថ្ងៃទី ១៣ ខែមិនា ឆ្នាំ២០០៩ |
| ភាគីដាក់ | ៖ | សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម | ៖ | ខ្មែរ (បកប្រែភាសាបារាំង) |
| ប្រភេទឯកសារ | ៖ | សម្ងាត់ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 03 / 2009
ម៉ោង (Time/Heure): 10:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

---

## ពាក្យស្នើសុំឲ្យពិចារណាឡើងវិញពាក់ព័ន្ធនឹងសក្ខីភាពនៃអត្តសញ្ញាណចាំបាច់ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

**ភាគីដាក់**

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
- លោក គីម ម៉េងឃី
- កញ្ញា ម៉ុច សុវណ្ណារី
- អ្នកស្រី Martine JACQUIN
- លោក Philippe CANONNE
- អ្នកស្រី Annie DELAHAIE
- អ្នកស្រី. Elisabeth RABESANDRATANA

**នៅចំពោះមុខ**

អង្គជំនុំជម្រះសាលាដំបូង
- ចៅក្រម និល ណុន ប្រធាន
- ចៅក្រម Silvia CARTWRIGHT
- ចៅក្រម យ៉ា សុខន
- ចៅក្រម Jean-Marc LAVERGNE
- ចៅក្រម ធូ មូណី

សហមេធាវីការពារ
- លោក ការ សាវុធ
- លោក François Roux

សហព្រះរាជអាជ្ញា
- លោកស្រី ជា លាង
- លោក Robert PETIT
- លោក យ៉េត ចរិយា
- លោក William SMITH
- លោក ពេជ្រ សម្បត្តិ
- លោក Alex BATES

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី
- លោក គង់ ពិសី
- លោក ហុង គីមសួន
- លោក យុង ផានិត
- អ្នកស្រី ទី ស្រីនណា
- អ្នកស្រី Silke STUDZINSKY
- លោក Pierre Olivier Sur
- លោក Karim KHAN
- លោក Alain WERNER
- កញ្ញា Brianne McGONIGLE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

## I. រំលឹកអំពីអង្គហេតុ និងនីតិវិធី

1. នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងឯកសារអត្តសញ្ញាណបណ្ណដែលត្រូវការសម្រាប់ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបានភ្ជាប់ទៅនឹងការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្ន E2/36 ក្នុងការផ្តល់ជូននូវពត៌មានបន្ថែមដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួនរហូតដល់ថ្ងៃទី ០៣ ខែមិនា ឆ្នាំ២០០៩ (សេចក្តីសម្រេច)[1] ។

2. នៅថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០០៩ អង្គជំនុំជម្រះសាលាដំបូងបានច្រានចោលគុណសម្បត្តិជាដើមបណ្តឹងរដ្ឋប្បវេណី E2/36 ដោយសារតែអវត្តមាននៃការទាក់ទាងឯកសារដែលអាចបញ្ជាក់ពីអត្តសញ្ញាណនៃដើមបណ្តឹង E2/36 ផ្តល់ជូនដោយអាជ្ញាធរមានសមត្ថកិច្ច[2] ។

3. ចាប់តាំងពីថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៩ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) មានបំណងដាក់ដើមបណ្តឹងដែលរស់នៅក្នុងភូមិ កាដូត ស្រុក អណ្តូងមាស ខេត្តរតនគិរី ។ មន្ត្រីម្នាក់ជាសមាជិកសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានចុះទៅដល់ទីកន្លែង ប៉ុន្តែមិនបានជួបដើមបណ្តឹងរូបនោះទេ ហើយសមាគមអន្តរការីក៏មានការលំបាកក្នុងការបញ្ជាក់ទីតាំងរបស់គាត់ដែរ E2/36 ។ ទីបញ្ចប់ សមាគមអាដហុក (ADHOC) បានធ្វើការទំនាក់ទំនងហើយបានផ្ញើរនូវអត្តសញ្ញាណបណ្ណថតចម្លង[3]មកការិយាល័យសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) ។

---

[1] E2/94

[2] E2/94/2

[3] ឯកសារភ្ជាប់នៅក្នុងឧបសម្ព័ន្ធ

E2/94/3



## II. ការស្នើសុំឲ្យមានការពិនិត្យឡើងវិញ

4. ដោយមានការពិបាកក្នុងការទាក់ទងដោយផ្ទាល់ រវាងដើមបណ្តឹងលេខ E2/36 និងអន្តរការី សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣) សូមធ្វើការស្នើសុំឲ្យមានការពិចារណាឡើងវិញពីគុណសម្បត្តិជាដើមបណ្តឹងលេខ E2/36 នៅក្នុងសំនុំរឿងលេខ ០០១/១៨-០៧-២០០៧ អវតក/អង្គជំនុំជម្រះសាលាដំបូង ។

## ហេតុដូច្នេះ

៥. សូមតុលាការមេត្តាទទួលយកគុណសម្បត្តិរបស់ដើមបណ្តឹងលេខ E2/36 ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំនុំរឿង ០០១/១៨-០៧-២០០៧ អវតក/អង្គជំនុំជម្រះសាលាដំបូង ដោយ អនុគ្រោះ ៕

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០០៩

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម៣)

មេធាវី គីម ម៉េងឃី | មេធាវី មុំ សុវណ្ណារី

Pour មេធាវី Martine JACQUIN | Pour មេធាវី Philippe CANONNE

Pour មេធាវី Annie DELAHAIE | Pour មេធាវី Elisabeth RABESANDRATANA